ក្រសួងយុត្តិធម៌

លេខ ១០៥៩ រប ៦១០៦-៩៤

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធាតុលាការ គ្រប់ខេត្ត ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** ភារៈកិច្ចអយ្យការអមតុលាការក្នុងករណីផ្ទេរទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ។

ខ្ញុំសូមជម្រាបមកលោកប្រធានតុលាការគ្រប់ខេត្ត ក្រុងថា តុលាការជាស្ថាប័នមួយមានភារៈកិច្ចជំនុំជម្រះរឿងក្តីគ្រប់ប្រភេទ ក្នុក្របខ័ណ្ឌអំណាចតុលាការដែលមានចែងក្នុងមាត្រា១០៩ នៃរដ្ឋធម្មនុញ្ញ ។ផ្នែកខាងរឿងអាជ្ញាកិច្ចការជំនុំជម្រះនៃតុលាការត្រូវប្រព្រឹត្តទៅក្រោយពីមានបណ្តឹងពីស្ថាប័នអយ្យការអមតុលាការ ឬក៏ថាពីអយ្យការធ្វើការក្បែរតុលាការដើម្បីប្តឹងចោទប្រកាន់លើជនប្រព្រឹត្តបទល្មើស ចង្អុលភស្តុតាងផ្សេងៗ ដើម្បីបញ្ជាក់អំពីពិរុទ្ធភាព ហើយសុំឲ្យតុលាការយកបញ្ញត្តិច្បាប់មកអនុវត្តធ្វើទោសដល់មនុស្សត្រូវចោទនោះ ។

ខ្ញុំសូមបញ្ជាក់ថា កិច្ចការស្វែងរកមនុស្សប្រព្រឹត្តបទល្មើសមានមន្ត្រីឬភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកបំពេញភារកិច្ចក្រោមការណែនាំរបស់ព្រះរាជអាជ្ញា ។

ចាប់តាំងពីមនុស្សត្រូវចោទជាប់ឃុំឃាំងជាបណ្តោះអាសន្នដល់ជននេះត្រូវទទួលការកាត់ទោសហើយក្លាយទៅជាទណ្ឌិតទទួលទោសនៅក្នុងពន្ធនាគារនោះព្រះរាជអាជ្ញាមានភារៈកិច្ចតាមឃ្លាំមើលការអនុវត្តន៍ នៃការយកផ្នែកពន្ធនាគារជារៀងរហូត ។

ដូច្នេះក្នុងករណីផ្ទេរទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀតជាភារៈកិច្ចត្រួតពិនិត្យ និងឃ្លាំមើលរបស់អយ្យការ ដែលជាអ្នកសរសេររាយការណ៍ទៅក្រសួងយុត្តិធម៌និងទៅមហាអយ្យការអមសាលាឧទ្ធរណ៍ដែលជាស្ថាប័នថ្នាក់លើនៃឋានានុក្រម ពុំមែនជាភារៈកិច្ចប្រធានតុលាការទេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**